សូមគោរពជូនឪពុកម្តាយ/អាណាព្យាបាលសិស្សសាលារដ្ឋ Shakopee

សូមអរគុណ យើងដឹងគុណអ្នកលើសពីអ្វីដែលអ្នកបានដឹង។ ការសិក្សាបានក្លាយជាបទពិសោធន៍ខុសគ្នាខ្លាំងណាស់សម្រាប់យើងទាំងអស់គ្នា ហើយយើងសូមកោតសរសើរចំពោះសមត្ថភាពរបស់អ្នកក្នុងការតស៊ូឆ្លងកាត់រាល់ឧបសគ្គទាំងអស់នេះ។ នៅពេលយើងបញ្ចប់ឆ្នាំសិក្សា 2019-20 យើងសង្ឃឹមថា អ្នក និងក្រុមគ្រួសាររបស់អ្នកសម្រាកលំហែកាយ និងរីករាយនៅរដូវក្តៅ!

នេះជាបច្ចុប្បន្នភាព និងព័ត៌មានសម្រាប់សប្តាហ៍នេះ៖

**ការស្ទង់មតិតាមដានអំពីការសិក្សាពីចម្ងាយ**

យើងចង់ស្តាប់យោបល់របស់អ្នកអំពីការសិក្សាពីចម្ងាយ។ ប្រសិនបើអ្នកមិនទាន់បានធ្វើការស្ទង់មតិទេ សូមបំពេញបែបបទដាច់ដោយឡែកសម្រាប់សិស្សម្នាក់ៗនៅក្នុងគ្រួសាររបស់អ្នក។ ចុច ទីនេះ ដើម្បីធ្វើការស្ទង់មតិ (រុស្ស៊ី, សូម៉ាលី, អង់គ្លេស អេស្ប៉ាញ)។

**ក្រឡេកមើលទៅខែកញ្ញា**

នារដូវក្តៅ សមាជិកនៃរដ្ឋបាល និងក្រុមគ្រូបង្រៀននៅក្នុងមណ្ឌលសាលានឹងត្រូវរៀបចំផែនការដោយផ្អែកលើទិសដៅរបស់ក្រសួងអប់រំនៃរដ្ឋ Minnesota និងក្រសួងសុខាភិបាលនៃរដ្ឋ Minnesota ដើម្បីធានាថា យើងផ្តល់ជូនសិស្សនិងបុគ្គលិករបស់យើងនូវបរិយាកាសសិក្សាប្រកបដោយសុវត្ថិភាពបំផុតតាមអាចធ្វើទៅបាន។ យើងនឹងផ្តល់ដំណឹងនៅពេលដែលទទួលបានព័ត៌មានលម្អិត។ សូមប្រាកដថាពិនិត្យមើលអ៊ីមែលរបស់អ្នកពេញមួយរដូវក្តៅដើម្បីទទួលបានព័ត៌មានថ្មីៗ។

**ទស្សនវិស័យហិរញ្ញវត្ថុរបស់មណ្ឌលសាលា**

ចាប់ពីឆ្នាំសិក្សាក្រោយ ថវិកាចំណាយរបស់យើងត្រូវបានប៉ាន់ស្មានថាមានទំហំធំជាងប្រាក់ចំណូលរបស់យើង។ នោះមិនមាននិរន្តរភាពទេ ដូច្នេះហើយមណ្ឌលសាលានឹងពិនិត្យមើលជម្រើសផ្សេងៗគ្នាដោយអនុវត្តតាមស្ថានភាពជាក់ស្តែងនៃហិរញ្ញវត្ថុរបស់សហគមន៍យើង។ គោលដៅរបស់យើងគឺត្រូវស្វែងរកមធ្យោបាយដើម្បីរក្សាឱកាសរៀបចំកម្មវិធី និងឱកាសរៀនសូត្រប្រកបដោយគុណភាពសម្រាប់សិស្សានុសិស្សរបស់យើង ខណៈពេលដែលកំពុងកសាងផ្លូវឆ្ពោះទៅស្ថិរភាពហិរញ្ញវត្ថុរយៈពេលវែង និងអាចទាក់ទាញ រក្សា និងផ្តល់សំណងសមរម្យសម្រាប់គ្រូមានសមត្ថភាពខ្ពស់។ ជម្រើសនានាដែលពិចារណារួមមានការកាត់បន្ថយថវិការួមជាមួយសំណើប្រតិបត្តិការយកពន្ធនៅសន្លឹកឆ្នោតសម្រាប់ការបោះឆ្នោតខែវិច្ឆិកា ឆ្នាំ 2020។

នៅថ្ងៃច័ន្ទទី 8 ខែមិថុនា កិច្ចសន្ទនាតាមអនឡាញរបស់សហគមន៍អំពីបញ្ហាប្រឈមផ្នែកហិរញ្ញវត្ថុរបស់មណ្ឌលសាលានឹងត្រូវបានផ្សាយផ្ទាល់តាម YouTube ចាប់ពីម៉ោង 4:30 ល្ងាចដល់ 5:30 ល្ងាច។ ចុច ទីនេះ ដើម្បីចូលរួមកិច្ចសន្ទនាសហគមន៍តាមរយៈការផ្សាយផ្ទាល់។ កិច្ចប្រជុំនេះនឹងចាប់ផ្តើមពីការធ្វើបទបង្ហាញរយៈពេល 20 នាទីដោយលោក Mike Redmond ជានាយកសាលា ពន្យល់អំពីបញ្ហាប្រឈមផ្នែកហិរញ្ញវត្ថុដែលមណ្ឌលសាលាកំពុងតែប្រឈមមុខ និងជម្រើសដែលក្រុមប្រឹក្សាភិបាលកំពុងធ្វើការពិចារណា។ បន្ទាប់ពីបទបង្ហាញនេះ លោក Mike Redmond ជានាយកសាលា លោក Bill Menozzi នាយកហិរញ្ញវត្ថុ និងលោក Kristi Peterson ប្រធានគណៈកម្មការសាលា នឹងចំណាយពេល 40 នាទីទៀតដើម្បីឆ្លើយតបនឹងសំណួររបស់ប្រជាសហគមន៍ទាក់ទងនឹងស្ថានភាពហិរញ្ញវត្ថុរបស់មណ្ឌលសាលា និងបញ្ហាប្រឈមនាពេលខាងមុខ។ សំណួរអាចត្រូវបានបញ្ជូនជាមុន ឬក្នុងអំឡុងពេលធ្វើបទបង្ហាញតាមរយៈការផ្ញើអ៊ីមែលទៅអាសយដ្ឋាន communications@shakopee.k12.mn.us។ យើងនឹងឆ្លើយសំណួរឲ្យបានច្រើនតាមដែលអាចទៅបាននៅក្នុងកិច្ចប្រជុំនេះ។

ក្នុងពេលទន្ទឹមនេះ៖

- ចុច ទីនេះ ដើម្បីចូលមើលគេហទំព័រការពិតអំពីហិរញ្ញវត្ថុពិសេសរបស់យើង។
- ចុច ទីនេះ ដើម្បីមើលវីដេអូអំពីស្ថានភាពនៃមណ្ឌលសាលាមកពីលោក Mike Redmond ជានាយកសាលា (វីដេអូ 7 នាទីនិយាយសង្ខេបអំពីការឆ្លើយតបរបស់មណ្ឌលសាលាចំពោះជំងឺ COVID-19) សូមក្រឡេកមើលទៅរដូវក្តៅ និងរដូវស្លឹកឈើជ្រុះ និងធ្វើការពិនិត្យជារួមលើបញ្ហាប្រឈមផ្នែកហិរញ្ញវត្ថុ។)
- ចុច ទីនេះ ដើម្បីមើលបទបង្ហាញរបស់នាយកសាលា Redmond ស្តីពីទស្សនវិស័យហិរញ្ញវត្ថុរបស់មណ្ឌលសាលា។ (វីដេអូ 20 នាទីពន្យល់អំពីបរិបទហិរញ្ញវត្ថុរបស់មណ្ឌលសាលា និងបង្ហាញជម្រើសផ្សេ

ងៗដែលគេកំពុងធ្វើការពិចារណាដើម្បីដោះស្រាយបញ្ហាប្រឈមនាពេលខាងមុខ។) ចុច ទីនេះ ដើម្បីពិនិត្យឡើងវិញនូវឯកសារ PowerPoint ដែលមាននៅក្នុងបទបង្ហាញនេះ។
- បន្ទាប់ពីបានពិនិត្យមើលទំព័រព័ត៌មាននៃការពិតអំពីហិរញ្ញវត្ថុហើយ សូមចំណាយពេលពីរបីនាទីដើម្បីបំពេញ ទម្រង់បែបបទផ្តល់មតិអំពីនីតិវិធីដំណើរការរៀបចំផែនការហិរញ្ញវត្ថុ នេះដើម្បីចែករំលែកទស្សនៈរបស់អ្នកអំពីដំណើរការរៀបចំផែនការនេះ។

**<u>អបអរសាទរចំពោះសិស្សវិទ្យាល័យ</u>**

សូមជួយយើងអបអរសាទរសិស្សជំនាន់ឆ្នាំ 2020។ យើងសូមជូនពរសិស្សបញ្ចប់ការសិក្សាទទួលបានលទ្ធផលល្អបំផុតនៅក្នុងកិច្ចខិតខំប្រែងប្រែងនាពេលអនាគត។  ចុច ទីនេះ ដើម្បីមើលវីដេអូប្រគល់រង្វាន់ជូនសិស្សវិទ្យាល័យរបស់យើង។

សូមអរគុណ<br>ក្រសួងទំនាក់ទំនងសាលារដ្ឋ Shakopee | communications@shakopee.k12.mn.us